ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខៈ ៣១០

ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៨

សាលដីកា

លេខៈ ១១ "I"

ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២០

# សាលដីកា

## តាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០

ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម ៖

១.ឯកឧត្តម [redacted] ប្រធានអង្គជំនុំជម្រះ

២.លោក [redacted] ចៅក្រម

៣.លោក [redacted] ចៅក្រម

៤.លោក [redacted] ចៅក្រម

៥.លោកស្រី [redacted] ចៅក្រមរបាយការណ៍

### ក្រឡាបញ្ជីសវនាការ

លោក [redacted]

### តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

### ដើម្បីជំនុំជម្រះ

លើពាក្យបណ្តឹងសាទុក្ខលេខ ៣៨៩ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] សឿន ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ១០២ ក្រV សស ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៨ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ ដែលមាន ៖

-ជនជាប់ចោទឈ្មោះ [redacted] សឿន ភេទប្រុស អាយុ៥៨ឆ្នាំ ជនជាតិខ្មែរ មុខរបរ លក់ដូរ ទីកន្លែងកំណើតនៅភូមិពង្រ ឃុំរការគយ ស្រុកកងមាស ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តស្វាយរៀង ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោះ [redacted] មានកូន ០២នាក់ ទោសពីមុនគ្មាន ។ (អ្នកប្តឹងសាទុក្ខ)

Scanned with CamScanner

**ជាប់ចោទពីបទ៖** លួច ប្រព្រឹត្តនៅភូមិតាប៉ោង ឃុំសង្កែ ស្រុករំដួល ខេត្តស្វាយរៀង កាលពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

-**ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ** [redacted] សុខណ្ណា ភេទស្រី អាយុ៥៥ឆ្នាំ ជនជាតិខ្មែរ មុខរបរ ធ្វើស្រែ ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តស្វាយរៀង ។

**អំពីអង្គហេតុ៖**

កាលពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៧ វេលាម៉ោង ០៦ និង៣០នាទីព្រឹក ឈ្មោះ [redacted] សឿន បានទូរស័ព្ទបញ្ជាឱ្យប្អូនថ្លៃឈ្មោះ [redacted] ចាន់រ៉ា ឱ្យឡើងទៅធ្វើម៉ូតូនៅចំណុចវត្តថ្មី ហៅ វត្តពាមអំពិល ស្ថិតនៅក្នុងភូមិតាប៉ោង ឃុំសង្កែ ស្រុករំដួល ខេត្តស្វាយរៀង យកទៅឱ្យខ្លួន ដើម្បីយកទៅលក់នៅខេត្តកំពង់ចាម ហើយក្រោយពីទទួលទូរស័ព្ទរួចឈ្មោះ [redacted] ចាន់រ៉ា ក៏ជិះកង់បីទៅវត្តថ្មី ដើម្បីរកលួចម៉ូតូ ។ ពេលចូលទៅដល់ក្នុងវត្ត ដោយឃើញនគរបាលឃាមនៅទីនោះឈ្មោះ [redacted] ចាន់រ៉ា ក៏ដើរចេញមកអែបរបងវត្តក៏ឃើញម៉ូតូ ០១គ្រឿង ម៉ាកគុបជ្រុង ជារបស់ឈ្មោះ [redacted] សុខណ្ណា ដែលបញ្ឈរទុកនៅមុខផ្ទះ ក៏លួចជិះចេញទៅ តែត្រូវបានកូនរបស់ជនរងគ្រោះឃើញទាន់ប្តឹងសមត្ថកិច្ច ហើយពេលជិះចេញបានប្រហែល ៧០ម៉ែត្រ ឃើញសមត្ថកិច្ចជិះដេញតាមដូច្នេះឈ្មោះ [redacted] ចាន់រ៉ា ក៏បានផ្តួលម៉ូតូចោលរត់គេចខ្លួន ហើយក៏ត្រូវបានសមត្ថកិច្ចដេញតាមចាប់ខ្លួនបានភ្លាមៗ រួចនាំមកប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំសង្កែដើម្បីសាកសួរ ។ ឯឈ្មោះ [redacted] សឿន ត្រូវជាបងថ្លៃរបស់ឈ្មោះ [redacted] ចាន់រ៉ា ដែលជាអ្នកផ្តើមគំនិត ក្រោយពីបានដឹងថាចាប់បានឈ្មោះ [redacted] ចាន់រ៉ា ហើយក៏បានរត់បាត់ពីមូលដ្ឋាន ។ ក្រោយពីសាកសួររួចសមត្ថកិច្ចក៏បានកសាងសំណុំរឿងបញ្ជូនមកអយ្យការចាត់ការតាមច្បាប់ ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៥៩ "ឝ" ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តស្វាយរៀង ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១.ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ចាន់រ៉ា ភេទប្រុស កើតថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០២ ជនជាតិខ្មែរ ជាអនីតិជន (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន ០៦(ប្រាំមួយ)ខែ ពីបទ លួច ប្រព្រឹត្តនៅភូមិតាប៉ោង ឃុំសង្កែ ស្រុករំដួល ខេត្តស្វាយរៀង កាលពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

២.ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សឿន ភេទប្រុស អាយុ៥៨ឆ្នាំ ជនជាតិខ្មែរ ជានីតិជន (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន ០២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៤.០០០.០០០(បួនលាន)រៀល ពីបទ អ្នកផ្តើមគំនិតក្នុងបទលួច ប្រព្រឹត្តនៅភូមិតាប៉ោង ឃុំសង្កែ ស្រុករំដួល ខេត្តស្វាយរៀង កាលពីថ្ងៃទី

Scanned with CamScanner

០៦ ខែកញ្ញា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៨ មាត្រា ៣៥៣ និង មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

៣.ប្រគល់វត្ថុចាប់យក មានកង់ពណ៌ខ្មៅ ចំនួន ០១(មួយ)គ្រឿង ទៅឱ្យម្ចាស់ដើមវិញ ។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៨ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ចាន់រ៉ា និងឈ្មោះ [redacted] ស៊ឿន នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨ ។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ១៩ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] ស៊ឿន ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៥៩ "ឆ" ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តស្វាយរៀង ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ១០២ ក្រV សស ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១.ទទួលបណ្តឹងឧទ្ធរណ៍លេខ ១៩ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] ស៊ឿន ទុកជាត្រឹមត្រូវតាមច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៥៩ "ឆ" ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តស្វាយរៀង ទុកជាបានការទាំងមូលដដែល ។

សាលដីកានេះ ជំនុំជម្រះ ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៨ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ។

បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងសាទុក្ខលេខ ៣៨៩ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] ស៊ឿន ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ១០២ ក្រV សស ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៨ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្តីសន្និដ្ឋានសុំថា ៖

យោងតាមមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ជនជាប់ចោទបានស្នើសុំឱ្យសាលាដំបូង និងសាលាឧទ្ធរណ៍ និងគ្រប់ដំណាក់កាលស៊ើបអង្កេតទាំងអស់ ជនជាប់ចោទបានសុំឱ្យឆែកលេខទូរស័ព្ទខ្លួន តើនៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៧ ដែលមានលេខ ០៦៦ ៥៣៤ ៦៤០២ បានទូរស័ព្ទទៅឈ្មោះ [redacted] ចាន់រ៉ា



Scanned with CamScanner

ឬអត់? និងទូរស័ព្ទរបស់ខ្លួនលេខ ០៩៧ ៦០៦ ៧៤៧៤ និងលេខ ០៧៨ ៧៦៥ ២៥៩ នោះ វាផ្ទុយនឹងបញ្ញត្តិដែលមានចែងក្នុងមាត្រានោះ ត្រង់ចំណុច ៦ ។

នៅក្នុងរឿងនេះ ជនជាប់ចោទបានបដិសេធគ្រប់នីតិវិធី និងពេលសវនាការ ដោយបានស្នើសុំឱ្យតុលាការជួយរកយុត្តិធម៌ និងជួយស៊ើបអង្កេតលើចំណុចទំនាក់ទំនងទូរស័ព្ទពីជនជាប់ចោទឈ្មោះ [redacted]ចាន់រ៉ា ដែលបានឆ្លើយដាក់ថាខ្លួនជាអ្នកបញ្ជានោះ តែភស្តុតាងទៀតពុំមាននោះឡើយ ។ ចំណុចនេះ សូមក្រុមប្រឹក្សាពិចារណាពីមូលដ្ឋានដាក់បន្ទុកលើជនជាប់ចោទ ដែលមានតែចម្លើយជនជាប់ចោទតែមួយគត់ តែពុំមានភស្តុតាងដែលពុំបានស៊ើបតាមរយៈទូរស័ព្ទនោះឡើយ ។ ដើម្បីយុត្តិធម៌ និងផលប្រយោជន៍ដល់ជនជាប់ចោទ សូមក្រុមប្រឹក្សាបង្វិលឱ្យសាលាឧទ្ធរណ៍ជំនុំជម្រះសាជាថ្មីឡើងវិញ ស៊ើបសើរើចំណុចនេះ ។

តំណាងមហាអយ្យការស្នើក្រុមប្រឹក្សាជំនុំជម្រះសម្រេច

១.ទទួលបណ្តឹងសាទុក្ខលេខ ៣៨៩ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted]ស៊ឿន ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២.គប្បីបញ្ជូនរឿងទៅសាលាឧទ្ធរណ៍ជំនុំជម្រះ ។

+ជនជាប់ចោទឈ្មោះ [redacted]ស៊ឿន បានឆ្លើយថា ៖ ខ្ញុំបាទអាយុ៥៨ឆ្នាំ រស់នៅក្នុងភូមិ១២បូរីកីឡា សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ។ នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៧ ខ្ញុំកំពុងហូបកាហ្វេ មានមេប៉ុស្តិ៍គេមកខ្ញុំថា ពូមានរឿងហើយ ខ្ញុំថាមានរឿងអី គេថាខ្ញុំតែទៅឈ្មោះ [redacted]ចាន់រ៉ា ឱ្យលួចម៉ូតូគេ ខ្ញុំបានឆ្លើយទៅវិញថា ឈ្មោះ [redacted]ចាន់រ៉ា ត្រូវជាប្អូនថ្លៃ តែជាមនុស្សជក់ថ្នាំញៀន ខ្ញុំមិនពាក់ព័ន្ធក្នុងទំនាក់ទំនងល្អ ឬអាក្រក់ជាមួយឈ្មោះនេះទេ ការចោទប្រកាន់ បរិហារ បង្កាច់កេរ្តិ៍ ខ្ញុំបាទទាំងស្រុង ខ្ញុំបាទសុំបដិសេធទាំងអស់លើការចោទប្រកាន់របស់ឈ្មោះ [redacted]ចាន់រ៉ា នេះ ។ ការដែលខ្ញុំចូលខ្លួនមកបំភ្លឺមិនមែនចូលមកដោះស្រាយទេ ។

សំណូមពរ ៖ សុំរកយុត្តិធម៌ឱ្យខ្ញុំផង ព្រោះខ្ញុំខូចកិត្តិយស សុំលើកលែងចោទប្រកាន់ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

Scanned with CamScanner

## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៨៩ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] សឿន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ ក៏ដូចជាសាលាដំបូងខេត្តស្វាយរៀងដែរ ដែលបានសម្រេចផ្តន្ទាទោសជនជាប់ចោទ [redacted] សឿន ពីបទផ្តើមគំនិតលួច ដោយសំអាងលើចម្លើយដាក់បន្ទុករបស់ជនជាប់ចោទម្នាក់ទៀតឈ្មោះ [redacted] ចាន់រ៉ា មិនទាន់មានមូលដ្ឋានគ្រប់គ្រាន់នៅឡើយ ព្រោះថា ពិរុទ្ធភាពរបស់ជនជាប់ចោទ [redacted] សឿន ត្រូវបានតុលាការកំណត់ដោយផ្អែកតែទៅលើចម្លើយដាក់បន្ទុករបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់រ៉ា ម្នាក់គត់ដែលថា ជនជាប់ចោទ [redacted] សឿន បានបញ្ជាឱ្យលួចតាមទូរស័ព្ទ ។ ប៉ុន្តែតាំងពីដំណាក់កាលស៊ើបអង្កេតមក ជនជាប់ចោទ បានប្រកែកមិនទទួលនូវចម្លើយឆ្លើយដាក់របស់ជនជាប់ចោទ [redacted] ចាន់រ៉ា ទេ ហើយនៅចំពោះមុខចៅក្រមស៊ើបសួរ ជនជាប់ចោទ [redacted] សឿន បានសុំឱ្យធ្វើការស៊ើបសួរតាមរយៈលេខទូរស័ព្ទរបស់ខ្លួន និង [redacted] ចាន់រ៉ា ក៏ដូចជានៅសាលាឧទ្ធរណ៍ផងដែរ ឃើញថា សំអាងហេតុរបស់សាលាឧទ្ធរណ៍ដែលថារយៈពេលហួសពីមួយឆ្នាំហើយ ពុំអាចឱ្យក្រុមហ៊ុនទូរស័ព្ទផ្តល់សម្លេងនេះបានទេ នោះ ជាសំអាងហេតុស្មានប៉ុណ្ណោះ នោះតុលាការកំពូលពិចារណាឃើញថា សាលាឧទ្ធរណ៍គប្បីធ្វើការស៊ើបសួរបន្ថែមអំពីទំនាក់ទំនងតាមទូរស័ព្ទ នៅមុន និងក្រោយអំឡុងពេលនៃការប្រព្រឹត្តបទល្មើសរបស់ជនជាប់ចោទទាំងពីរ ដែលជាមូលដ្ឋានសំខាន់ក្នុងការដាក់ពិរុទ្ធភាពលើជនជាប់ចោទ ឃើញថា បណ្តឹងសាទុក្ខរបស់ជនជាប់ចោទ មានមូលហេតុត្រឹមត្រូវតាមច្បាប់ ។

៣-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ១០២ ក្រV សស ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៨ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ ពុំត្រឹមត្រូវតាមច្បាប់ទេ ។

## ហេតុដូច្នេះ

## សម្រេច

១.ទទួល បណ្តឹងសាទុក្ខលេខ ៣៨៩ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] សឿន។

២.បដិសេធ សាលដីកាព្រហ្មទណ្ឌលេខ ១០២ ក្រV សស ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៨ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ ទាំងមូល ។

៣.បង្វិល សំណុំរឿងព្រហ្មទណ្ឌលេខ ៣១០ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៨ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីស៊ើបសួរបន្ថែម និងជំនុំជម្រះឡើងវិញ ។

Scanned with CamScanner

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ ។

Scanned with CamScanner